# អភិបូជាសំណាក់ធម៌បព្វជិតបព្វជិតា
# ធ្វើនៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូល
# ភ្នំពេញថ្មី ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២

## “ក្រីក្រដែលសុខចិត្តលះបង់ចោល”

**អត្ថបទទី១៖ យ៉ាកុប ៥,១៣-២០**

ពាក្យអធិស្ឋានដែលផុសចេញមកពីជំនឿ នឹងសង្គ្រោះអ្នកជំងឺនោះ។ យក ៥,១៥

**ដំណឹងល្អ៖ ម៉ាកុស ១០,១៣-១៦**

អ្នកណាមិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ ដូចក្មេងតូចមួយទទួលទេ អ្នកនោះមិនអាចចូលក្នុងព្រះរាជ្យព្រះអង្គឡើយ។ មក ១០,១៥

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ យើងជួបជុំគ្នាជាមួយលោកឪពុក បងស្រីបងប្រុស ដែលជាប្រធាននៅក្នុងក្រុមបព្វជិតបព្វជីតានីមួយៗនៅក្នុងភូមិភាគភ្នំពេញ។ នៅពេលយើងឃើញក្រុមរបស់យើងដែលមានច្រើន នៅក្នុងភូមិភាគភ្នំពេញយើងជិត៣០ក្រុម។ នៅពេលខ្ញុំអង្គុយអំបាញ់មិញ ខ្ញុំបានមើលបងប្អូននិងចាប់អារម្មណ៍ដែរ ដោយសារយើងមកពីប៉ុន្មានប្រទេស។ នៅទីនេះយើងជាតំណាងនៃទ្វីបអាស៊ី មានខ្មែរ មានវៀតណាម មានថៃ មានជប៉ុន មានកូរ៉េ មានហ្វីលីពីន មានឥណ្ឌា មានខ្លះមកពីអាមេរិកខាងត្បូងដែរ។ ដូច្នេះ ពេលយើងឃើញគ្រួសារមួយយ៉ាងពិសេស ដែលមកពីប្រទេសផ្សេងៗពីគ្នា ដែលមានរបៀបនិងបេសកកម្មផ្សេងពីគ្នា។ ប៉ុន្តែ ពេលយើងមកថ្វាយអភិបូជានេះយើងយល់ថា អ្វីៗទាំងអស់ដែលណែនាំឲ្យយើងជាមនុស្សខុសៗគ្នា ទៅជាទ្រព្យសម្បត្តិដល់កំពូល។ យើងដឹងថា នៅក្នុងព្រះយេស៊ូតាមពិតយើងជាក្រុមគ្រួសាតែមួយ។

ថ្ងៃនេះ ព្រះយេស៊ូដឹកនាំយើងមែនទែន ដើម្បីឲ្យយើងមានផ្លូវតែមួយ ដើម្បីធ្វើដំណើររួមជាមួយគ្នា និងដើម្បីបំពេញបេសកកម្មរបស់យើង ដែលជាអ្នកប្រកាសដំណឹងល្អ អ្នកកសាងព្រះរាជរបស់ព្រះជាម្ចាស់ នៅលើទឹកដីប្រទេសកម្ពុជា។ នៅក្នុងអត្ថបទទី១ យើងបានស្តាប់មួយចំណុចដ៏

សំខាន់ "**ដូច្នេះសូមបងប្អូនលន់តួបាបឲ្យគ្នាទៅវិញទៅមក ព្រមទាំងអធិដ្ឋានឲ្យគ្នាទៅវិញទៅមកផង ដើម្បីឲ្យបានជាសះស្បើយផង**"។ យើងជិតចូលនៅក្នុងរដូវ៤០ថ្ងៃ ជាពេលវេលាដើម្បីមើលឃើញដល់ជម្ងឺនានារបស់យើង ជាពិសេសតាមផ្លូវវិញ្ញាណ តាមផ្លូវចិត្ត។ ជាពេលវេលាដើម្បីកែប្រែចិត្តគំនិត ជាពេលវេលាដើម្បីឲ្យយើងដឹងថា យើងត្រូវតែអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក។ ខ្ញុំគិតថា នៅពេលលោកយ៉ាកុបដាស់តឿនយើង ទី១ឲ្យយើងលើកលែងទោសឲ្យគ្នាទៅវិញទៅមក ទី២ឲ្យយើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ទី៣ឲ្យយើងអប់រំគ្នាទៅវិញទៅមក។ នេះជាផ្លូវតែមួយ ដើម្បីណែនាំឲ្យយើងចូលគ្នា ជាក្រុមគ្រួសាតែមួយនៅក្នុងព្រះយេស៊ូពិតមែន។

ដូច្នេះ យើងមកពីវប្បធម៌ផ្សេងគ្នា យើងមកពីក្រុមបព្វជិតបព្វជិតាផ្សេងគ្នា ប៉ុន្តែនៅក្នុងព្រះគ្រីស្តពិតប្រាកដមែនយើងជាអង្គតែមួយ ផ្លូវតែមួយដ៏ពិតប្រាកដ។ ប៉ុន្តែ នៅពេលយើងមើលព្រះយេស៊ូរបៀបដែលព្រះយេស៊ូអប់រំយើងថ្ងៃនេះ គឺណែនាំឲ្យយើងទាំងអស់គ្នាត្រូវតែចូលនៅក្នុងនេះ "**មានតែអ្នកដែលមានចិត្តដូចក្មេងៗទាំងនេះប៉ុណ្ណោះ ដែលចូលនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បាន**"។ សម្រាប់បងស្រីមួយចំនួនអត្ថបទនេះ ជាមូលដ្ឋាននៃផ្លូវវិញ្ញាណដែលអ្នកបង្កើតក្រុមបានជ្រើសរើស។ សម្រាប់យើង គឺជាមូលដ្ឋានមួយសំខាន់ណាស់ដើម្បីណែនាំឲ្យយើងអាចទៅមុខ នៅក្នុងបេសកកម្មរបស់យើង និងជាអង្គតែមួយនៅក្នុងការងារប្រចាំថ្ងៃ។ ដោយដឹងថា យើងមានព្រះបិតាដែលស្រឡាញ់យើង និងណែនាំឲ្យយើងមានចិត្តគំនិតដូចកូនក្មេង។ មានន័យថា យើងទីពឹងទៅលើព្រះបិតា យើងទីពឹងទៅលើឧបការគុណរបស់ព្រះជាម្ចាស់ មិនមែនយើងដែលសម្រេចចិត្ត មិនមែនយើងដែលចង់ធ្វើនេះ ធ្វើនោះ។ ប៉ុន្តែ យើងទទួលបេសកកម្មពីព្រះបិតា ដូចកូនក្មេងម្នាក់ទីពឹងលើឪពុកម្តាយ ចង់មានម្ហូបអាហារឪពុកម្តាយត្រូវការឲ្យ ចង់ទៅពីកន្លែងមួយទៅកន្លែងមួយពេលនៅតូច បើគ្មានឪពុកម្តាយមិនអាចទៅណាបានទេ។ ដូច្នេះ នៅពេលយើងចូលនៅក្នុងរបៀបព្រះយេស៊ូដែលអប់រំយើង យើងដឹងថានៅក្នុងផ្លូវវិញ្ញាណពិតមែនយើងជាក្រុមតែមួយ យើងជាព្រះសហគមន៍តែមួយ។ យើងជាបងប្អូនគ្នាដ៏ពិតប្រាកដដែលខិតខំពីមួយថ្ងៃទៅមួយថ្ងៃ កែប្រែចិត្តគំនិតដើម្បីមានចិត្តដូចក្មេងៗដែលព្រះយេស៊ូចេះតែស្វាគមន៍ ចេះតែអាណិត ចេះតែដឹកនាំ ចេះតែអប់រំ ចេះតែលើកទឹកចិត្ត។ នេះជាជីវិតរបស់យើងជាបព្វជិតបព្វជិតា ជាអ្នកបួស ដែលប្រកាសដំណឹងល្អនៅប្រទេសកម្ពុជា។ ដូច្នេះ យើងនឹកឃើញរបៀបដែលយើងរស់នៅ ដើម្បីអធិដ្ឋាន ដើម្បីស្រឡាញ់ ដើម្បីចែករំលែក។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ម៉ារីរី សម្រាប់ម៉ារីអង់ ដែលទាំងពីរមានម៉ារីនៅជាមួយ ដើម្បីណែនាំឲ្យយើងនឹកឃើញដល់ពាក្យសច្ចារបស់យើង ដែលសុខចិត្តលះចង់ចោលដើម្បី

រស់នៅជាមួយព្រះយេស៊ូ នៅក្នុងព្រហ្មចារិនីភាព នៅក្នុងការស្តាប់បង្គាប់ និងនៅក្នុងរបៀបរស់នៅជាអ្នកក្រីក្រ។ មានន័យថា មិនមែនអ្នកក្រីក្រដោយសារយើងអត់មានអ្វីសោះ តាមពិតយើងមានច្រើនណាស់។ ពេលយើងឈឺយើងមានមន្ទីរពេទ្យ ពេលយើងអស់កម្លាំងក៏យើងទៅលេងប្រទេសយើងបាន នៅពេលយើងមានបញ្ហាមួយដែលកើតឡើងក្រុមគ្រួសាររបស់យើងក៏ជួយឧបត្ថម្ភដែរ។ ដូច្នេះ ភាពក្រីក្ររបស់យើងក៏មិនមែនក្រីក្រដែលអត់មានអ្វីសោះ ប៉ុន្តែភាពក្រីក្ររបស់យើងជារបៀបពិសេស ជាភាពក្រីក្រដែលសុខចិត្តលះបង់ចោលមែន។ លោកីយ៍មិនយល់ទេ ពេលយើងប្រើពាក្យនេះ ប៉ុន្តែយើងលះបង់ចោលដើម្បីទីពឹងទៅលើព្រះជាម្ចាស់ ដើម្បីទីពឹងទៅលើឧបការគុណរបស់ព្រះអង្គ ដើម្បីទីពឹងទៅលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ជានិច្ច។

ដូច្នេះ ថ្ងៃនេះយើងអរព្រះគុណព្រះអង្គ យើងឃើញបងប្រុស ប្រ៊ូង់ស៊ីស ដែលពោរពេញដោយអំណរសប្បាយដែលមកពីព្រះជាម្ចាស់ លោកអភិបាល អ៊ីវ ក៏ដូចគ្នាដែរ។ លោកអភិបាល អ៊ីវ អ្នកណាក៏ស្គាល់ស្នាមញញឹមរបស់គាត់ អ្នកណាក៏ស្គាល់របៀបដែលគាត់សើច។ ណែនាំឲ្យយើងយល់ថា ពេលយើងធ្វើជីវិតទៅលើព្រះជាម្ចាស់ ដូចកូនក្មេងម្នាក់យើងទទួលអំណរសប្បាយ។ អំណរសប្បាយយ៉ាងពិសេស ដោយសារជាអំណរសប្បាយដែលមកពីព្រះជាម្ចាស់ផ្ទាល់។ នេះជាលក្ខណៈរបស់យើងជាបុព្វជិតបុព្វជិតា ជាគ្រីស្តបរិស័ទ ដែលបានធ្វើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មិតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/Z4Tsm3Moq_k